ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខ :...៣៥៩...ប្រក...បស្ថ

ប្រកាស

ស្តីពី

ការទទួលស្គាល់ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ «នាពិសី»
នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតក្នុងភូមិនាពិសី
ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញលិខិតចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«នាពិសី»**
- យោងតាមតម្រូវការចាំបាច់

សម្រេច

ប្រការ១._ ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ**«នាពិសី»** នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតក្នុងភូមិនាពិសី ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង។

ប្រការ២._ សហគមន៍តំបន់ការពារធម្មជាតិ**«នាពិសី»** នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង មានផ្ទៃដីទំហំ**៥២១ហិកតា** ដូចមានផែនទីជាឧបសម្ព័ន្ធ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា ដូចក្នុងតារាងខាងក្រោម៖

ID	ចំណុច	X	Y	ID	ចំណុច	X	Y
1	A	៣៨៥០៨០	១២៣៣៩១១	14	N	៣៨២៥៥៧	១២៣៥៧២៥
2	B	៣៨៥០៤៨	១២៣៣៩៥៦	15	O	៣៨២១៧៩	១២៣៥៣៧៤
3	C	៣៨៤៩៣៤	១២៣៣៩៧៤	16	P	៣៨២២៣៤	១២៣៤៩០១
4	D	៣៨៤៨៧៥	១២៣៤១៣៤	17	Q	៣៨២០១២	១២៣៤៦៣៨
5	E	៣៨៤៥៨៩	១២៣៤៣៩០	18	R	៣៨២០៥៨	១២៣៤២៥០
6	F	៣៨៤៥០៧	១២៣៤៧៩០	19	S	៣៨២២៥៨	១២៣៣៦៥៧
7	G	៣៨៤១២០	១២៣៤២៧២	20	T	៣៨២៦២៦	១២៣៣២២៧
8	H	៣៨៣៧៥៤	១២៣៤៧៤៨	21	U	៣៨២៩៨៥	១២៣៣៣១៩
9	I	៣៨៣៤៦២	១២៣៤៣៧៥	22	V	៣៨៣១៥៣	១២៣២៥១៨
10	J	៣៨៣២៨០	១២៣៥១៥៨	23	W	៣៨៣៣០៨	១២៣២២៧១
11	K	៣៨៣៤៩៤	១២៣៥៤៥៨	24	X	៣៨៣៤៦៥	១២៣២១៣៤
12	L	៣៨២៥៩៧	១២៣៥០២៩	25	Y	៣៨៣៥៦៧	១២៣២១៩៤
13	M	៣៨២៦៣៨	១២៣៥៥០៨				

ប្រការ៣._ សហគមន៍តំបន់ការពារធម្មជាតិ **«នាពិសី»** នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ត្រូវចុះកិច្ចព្រមព្រៀងជាមួយ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ **«នាពិសី»** ត្រូវរៀបចំលក្ខន្តិក: និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

ប្រការ៤._ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៥._ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ឧទ្ធកាល័យរដ្ឋមន្ត្រី អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង នាយកដែនជម្រកសត្វព្រៃពាមក្រសោប និងសហគមន៍តំបន់ការពារធម្មជាតិ«នាពិសី» ត្រូវអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕


រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

សាយ សំអាល់

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ឧទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកោះកុង
- ដូចប្រការ៥ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទី សហគមន៍តំបន់ការពារធម្មជាតិ "នាពិសី" នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង
ស្ថិតក្នុងភូមិសាស្ត្រឃុំជីខក្រោម ស្រុកស្រែ អំបិល ខេត្តកោះកុង



ឧបសម្ព័ន្ធ: ប្រកាសលេខ ៣៥៩ ប្រគ.
ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៦
រេសក្រសួងបរិស្ថាន

ID	POINT	X	Y
1	A	345080	1233911
2	B	345048	1233956
3	C	344934	1233974
4	D	344875	1234134
5	E	344589	1234390
6	F	344507	1234790
7	G	344120	1234272
8	H	343754	1234748
9	I	343462	1234375
10	J	343280	1235158
11	K	343494	1235458
12	L	342597	1235029
13	M	342638	1235508
14	N	342557	1235725
15	O	342179	1235374
16	P	342234	1234901
17	Q	342012	1234638
18	R	342058	1234250
19	S	342258	1233657
20	T	342636	1233227
21	U	342985	1233319
22	V	343153	1232518
23	W	343308	1232271
24	X	343465	1232134
25	Y	343567	1232194